**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ១៤៣ MOC / SM 2007

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៧

# ប្រកាស
# ស្តីពី
# ការបង្កើតការិយាល័យតម្កល់ប្រតិបត្តិការមានកិច្ចធានា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើ ប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ ប្រកាសអោយ ប្រើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## <u>សំរេច</u>

**ប្រការ ១:** ត្រូវបានបង្កើតការិយាល័យតម្កល់ប្រតិបត្តិការ ដែលមានកិច្ចធានាស្ថិតនៅក្រោមនាយកដ្ឋាននីតិកម្ម ដែលមានភារកិច្ចគ្រប់គ្រងការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីធ្វើសុក្រឹតកម្ម សិទ្ធិប្រាតិភោគលើទ្រព្យធានា ។

**ប្រការ ២:** នាយិកាខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានទីតិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក ត្រូវ អនុវត្តប្រកាសនេះ ។

**ប្រការ ៣:** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប និង ផ្សព្វផ្សាយ"
- គ្រប់មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ